# សង្ខេបគោលនយោបាយ

## ភាពជាដៃគូរវាងរដ្ឋបាលមូលដ្ឋាន និងវិស័យឯកជនក្នុងការផ្តល់សេវាសាធារណៈ៖

### ករណីនៃការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា



គ.ជ.អ.ប NCDD
Australian Aid
ពន្លកចំណេះ
The Asia Foundation
CENTER FOR SUSTAINABLE WATER

## អំណះអំណាង

ការសិក្សានេះទទួលបានការគាំទ្រពី ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី តាមរយៈកម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាសម្រាប់ការអភិវឌ្ឍនៅកម្ពុជា របស់អង្គការមូលនិធិអាស៊ី។ ទស្សនៈដែលបានលើកឡើងក្នុងការសិក្សានេះ គឺជាទស្សនៈផ្ទាល់របស់អ្នកនិពន្ធផ្ទាល់ ពោលគឺមិនបានឆ្លុះបញ្ចាំងពីទស្សនៈ និងការយល់ឃើញរបស់រដ្ឋាភិបាលអូស្ត្រាលី និងអង្គការមូលនិធិអាស៊ី ឬគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឡើយ។

© អង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព ២០២៣

## ១. សេចក្តីផ្តើម

អស់រយៈពេលជាងមួយទសវត្សរ៍មកហើយ ដែលរដ្ឋាភិបាលបានផ្តួចផ្តើមដំណើរការវិមជ្ឈការ និងវិសហមជ្ឈការដោយមានគោលបំណងបង្កើនការឆ្លើយតបទៅនឹងការផ្តល់សេវាធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាព និងលើកកម្ពស់គណនេយ្យភាព។ ក្រោមកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ទំនួលខុសត្រូវក្នុងការផ្តល់សេវារបស់រដ្ឋាភិបាលត្រូវបានផ្លាស់ប្តូរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) រួមមាន ឃុំ/សង្កាត់ ស្រុក ក្រុង ឬខណ្ឌក៏ដូចជារាជធានី និងថ្នាក់ខេត្ត។ ការពង្រឹងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈ គឺជាគន្លឹះនៃភាពជោគជ័យនៃកំណែទម្រង់នេះ។ នៅឆ្នាំ២០២១ រាជរដ្ឋាភិបាលក៏បានអនុម័តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ (NP-SNDD) ដំណាក់កាលទី២ ដែលសង្កត់ធ្ងន់លើតួនាទីនៃការរៀបចំផែនការរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាព និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដ៏រឹងមាំសម្រាប់វិមជ្ឈការសារពើពន្ធ។

ការផ្គត់ផ្គង់ទឹកស្អាត រួមទាំងទឹកតាមបំពង់ គឺជាសេវាកម្មសំខាន់មួយដែលត្រូវកែលម្អតាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្នុងការផ្តល់សេវានេះ រដ្ឋាភិបាលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអាច

1. ផ្តល់សេវាដោយផ្ទាល់ ឬ
2. ដើរតួជានិយតករ និងអ្នកសម្របសម្រួលសម្រាប់ប្រតិបត្តិករឯកជន

នៅក្នុងប្រទេសកម្ពុជា ការយកចិត្តទុកដាក់ភាគច្រើនគឺទៅលើចំនុចទីមួយ ប៉ុន្តែតិចតួចទៅលើចំនុចទីពីរ។ ការបង្រួមទំហំសារពើពន្ធដែលមានកម្រិតស្រាប់របស់រដ្ឋាភិបាល ដោយសារតែវិបត្តិកូវីដ-១៩ បង្ហាញថា តួនាទីទីពីរគួរតែត្រូវបានយកចិត្តទុកដាក់បន្ថែមទៀតនៅក្នុងឆ្នាំខាងមុខ។ ទិន្នន័យដែលមានបានបង្ហាញថាមានការគាំទ្រផ្នែកហិរញ្ញប្បទានកាន់តែច្រើនពីដៃគូរក្រៅរដ្ឋាភិបាល និងការវិនិយោគឯកជនក្នុងការផ្តល់សេវាកម្ម ជាពិសេសការផ្គត់ផ្គង់ទឹកស្អាតសាធារណៈទាំងនៅតំបន់ជនបទ និងទីក្រុង។

ទោះជាយ៉ាងណាក៏ដោយ ភាពជាដៃគូបច្ចុប្បន្នរវាងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន (PWOs) មិនទាន់អភិវឌ្ឍបានល្អនៅឡើយទេ។ យោងតាមគោលនយោបាយដែលមានស្រាប់ ថ្នាក់ស្រុក ក្រុង ឬខណ្ឌ គឺជាកម្រិតចម្បងសម្រាប់ការផ្តល់សេវា រួមទាំងទឹកស្អាតផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីជាងមួយទសវត្សរ៍នៃវិមជ្ឈការ និងវិសហមជ្ឈការ កម្រិតស្រុក ក្រុង ឬខណ្ឌ ទទួលបានធនធានតិចបំផុត បើធៀបនឹងកម្រិតរាជធានី/ខេត្ត និងឃុំ/សង្កាត់។ លើសពីនេះ ខណៈពេលដែលគោលនយោបាយរបស់រដ្ឋាភិបាលទទួលស្គាល់ពីសារៈសំខាន់នៃការធ្វើការជាមួយវិស័យឯកជនដើម្បីកែលម្អសេវាក្នុងតំបន់ តួនាទីរបស់រដ្ឋបាលក្រុង ស្រុក ក្នុងរឿងនេះ មិនទាន់ត្រូវបានកំណត់ឱ្យបានច្បាស់លាស់នោះទេ ហើយក៏មិនមានយន្តការជាក់ស្តែងណាមួយត្រូវបានដាក់ឱ្យដំណើរការដែរ។ ដែនកំណត់

នេះមិនត្រឹមតែធ្វើឱ្យអន់ថយតួនាទីរបស់រដ្ឋបាលស្រុក ក្រុង ឬខណ្ឌ ប៉ុណ្ណោះទេ ថែមទាំងរាំងស្ទះដល់ការកំណត់គោលដៅ និងគណនេយ្យភាពជុំវិញការវិនិយោគទឹកតាមបំពង់ និងការផ្តល់សេវាផងដែរ។

## ២. គោលបំណងស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងស្វែងយល់អំពីស្ថានភាពបច្ចុប្បន្ន និងការរៀបចំនាពេលអនាគតដែលរដ្ឋបាលមូលដ្ឋាន ជាពិសេសរដ្ឋបាលស្រុក/ក្រុង អាចធ្វើការយ៉ាងជិតស្និទ្ធជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដើម្បីកែលម្អសេវាទឹកតាមបំពង់។ ការសិក្សានេះធ្វើឡើងដើម្បីឆ្លើយសំនួរខាងក្រោម៖

- តើតួនាទី ការរៀបចំស្ថាប័ន និងបញ្ហាប្រឈមបច្ចុប្បន្នរបស់រដ្ឋបាលស្រុក/ក្រុង ក្នុងភាពជាដៃគូជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមានអ្វីខ្លះ?
- តើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមានតួនាទី និងបញ្ហាប្រឈមអ្វីខ្លះ?
- តើគួរតែមានតួនាទី ការរៀបចំការងារ និងយន្តការបែបណា ដើម្បីជានាភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងតួអង្គទាំងពីរ?

## ៣. វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះដឹកនាំដោយ អង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព (CSW) ដោយមានកិច្ចសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD-S) និងយុវជនស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ (VMC) នៃក្រសួងអប់រំ យុវជន និងកីឡា។

ការស្រាវជ្រាវនេះរួមមានសកម្មភាពដូចខាងក្រោម៖

- សម្ភាសន៍ជាមួយរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលធ្វើការលើវិស័យពាក់ព័ន្ធនឹងទឹក
- ពិនិត្យគោលនយោបាយ និងឯកសារពាក់ព័ន្ធ
- ការប្រមូលទិន្នន័យ និងការវិភាគ
- ការចុះអង្កេតជាមួយរដ្ឋបាលខេត្ត ស្រុក ឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងប្រជាពលរដ្ឋ រួមទាំងក្រុមជនងាយរងគ្រោះផងដែរ

ស្រុកគោលដៅសម្រាប់ការសិក្សានេះ

- ស្រុកសង្កែ ក្នុងខេត្តបាត់ដំបង
- ស្រុកស្អាងក្នុងខេត្តកណ្ដាល
- ស្រុកឈូក ក្នុងខេត្តកំពត
- ស្រុករុក្ខគិរី ក្នុងខេត្តបាត់ដំបង

ស្រុកចំនួនបួនត្រូវបានជ្រើសរើសដោយផ្អែកលើកម្រិតនៃនគរូបនីយកម្ម ការគ្របដណ្ដប់ដោយសេវាទឹកតាមបំពង់របស់ប្រតិបត្តិករឯកជន និងចំនួនប្រតិបត្តិករទឹកតាមបំពង់ឯកជននៅក្នុងតំបន់។ ដោយសារពេលវេលា និងធនធានមានកម្រិត ទំហំសំណាកនៃការសិក្សានេះគឺតូច។ តែទោះជាយ៉ាងណាក៏ដោយ ការរកឃើញអាចត្រូវបានប្រើជាសម្មតិកម្មដែលអាចត្រូវបានផ្ទៀងផ្ទាត់តាមរយៈទំហំសំណាកធំជាងនេះ ប្រសិនបើចាំបាច់។

## ៤. ការរកឃើញសំខាន់ៗ

ការផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា គ្រប់គ្រងដោយក្រសួងចំនួនពីរ គឺ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (MISTI)

ក្រសួងអភិវឌ្ឍន៍ជនបទ (MRD)

MISTI គ្រប់គ្រងការផ្គត់ផ្គង់ទឹកតាមបំពង់បែបអាជីវកម្មដែលផ្ដល់ដោយប្រតិបត្តិករទឹកឯកជន និងប្រព័ន្ធទឹកសាធារណៈដែលមានច្បាប់បទប្បញ្ញត្តិ និងស្តង់ដារច្បាស់លាស់ទាក់ទងនឹងអាជ្ញាប័ណ្ណ តម្លៃ តម្រូវការបច្ចេកទេស និងគុណភាព។

MRD គ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាតដែលគ្រប់គ្រងដោយសហគមន៍ ជាទូទៅមានតម្រូវការបច្ចេកទេស និងតម្លៃទាប ទំហំហេដ្ឋារចនាសម្ព័ន្ធតូច និងកម្រិតជំនួយខ្ពស់។

លទ្ធភាពទទួលបានប្រភពទឹកផឹកដែលមានការកែលម្អ[1]នៅកម្ពុជា បានកើនឡើងពី

៥៥% ក្នុងឆ្នាំ ២០១៤

មក ៨០% ក្នុងឆ្នាំ ២០១៩/២០២០។

## គម្លាតនៃការតភ្ជាប់ទឹកតាមបំពង់




ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានៅតែមានជាពិសេសរវាងប្រជាជននៅទីក្រុង និងជនបទ។ ប្រហែល ៨២% នៃគ្រួសារនៅក្នុងរាជធានីភ្នំពេញបានតភ្ជាប់ទឹកតាមបំពង់ ខណៈដែលមានប្រហែល ៣៣% នៃគ្រួសារនៅតំបន់ទីប្រជុំជនផ្សេងទៀត និងមានតែ ១០% នៃគ្រួសារនៅតំបន់ជនបទប៉ុណ្ណោះដែលមានទឹកតាមបំពង់ប្រើប្រាស់។ ប្រភពទឹកផឹកដែលមានការកែលម្អនឹងដែលត្រូវបានប្រើប្រាស់ជាទូទៅគឺទឹកអណ្តូងដែលមានប្រហែល ៣៨% នៅតំបន់ជនបទ និង ២៤% នៅតំបន់ទីប្រជុំជនផ្សេងទៀត ប៉ុន្តែមានតែ ៤.៥% ប៉ុណ្ណោះនៅក្នុងទីក្រុងភ្នំពេញ។ នៅមានគ្រួសារជាច្រើនប្រហែល ១២% នៅតំបន់ជនបទនៅបន្តប្រើប្រាស់ទឹកស្រះ ទន្លេ ឬអូរ។[2]

[1] ប្រភពទឹកផឹកដែលមានការកែលម្អ រួមមានទឹកតាមបំពង់នៅក្នុងលំនៅដ្ឋាន ទឹកតាមបំពង់ចូលទៅក្នុងបរិវេណ ទីធ្លា ឬដីឡូត៍ ក្បាលរ៉ូប៊ីណេសាធារណៈ អណ្តូងជីក ឬអណ្តូងខួង អណ្តូងដែលមានការការពារ ទឹកក្រោមដីដែលមានការការពារ ការប្រមូលទឹកភ្លៀង និងទឹកដប។

[2] របាយការណ៍អង្កេតសេដ្ឋកិច្ចសង្គមកម្ពុជា ២០១៩/២០២០

សម្រាប់ការផ្គត់ផ្គង់ទឹកនៅជនបទ សមិទ្ធិផលសំខាន់ៗរួមមាន ការពង្រឹងក្រុមការងារថ្នាក់ខេត្ត (PWGs) ការបង្កើត និងពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រង (MIS) និងការបង្កើត និងពង្រឹងការសម្របសម្រួលបច្ចេកទេសលើការផ្គត់ផ្គង់ទឹកនៅជនបទ។[3]

ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែមានដូចជា ហិរញ្ញវត្ថុ សមត្ថភាពស្ថាប័ន និងការសម្របសម្រួល (ការធ្វើផែនការប្រកបដោយប្រសិទ្ធភាព ថវិកា ការគ្រប់គ្រង និងការចូលរួមពីវិស័យឯកជន) និងកង្វះការរួមបញ្ចូលការប្រែប្រួលអាកាសធាតុ និងហានិភ័យគ្រោះមហន្តរាយទៅក្នុងការរចនា និងការគ្រប់គ្រង។

ម៉្យាងវិញទៀត បញ្ហាសម្របសម្រួលកើតឡើងដោយសារក្រសួងជាច្រើនរបស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងក្រុមហ៊ុនឯកជនដើរតួនាទីជាច្រើនក្នុងវិស័យទឹកស្អាត ប៉ុន្តែមិនមានសមាហរណកម្ម និងការសម្របសម្រួលគ្រប់គ្រាន់។

សម្រាប់ការផ្គត់ផ្គង់ទឹកក្នុងទីក្រុង MISTI គឺជាក្រសួងឈានមុខគេ។ ប្រកាសសំខាន់ៗជាច្រើនត្រូវបានចេញដូចជា ប្រកាសលេខ

- #៤៦១ ស្តីពីអាជ្ញាប័ណ្ណ
- #០៧៧ ការត្រួតពិនិត្យជាទៀងទាត់
- #០៨៤ ស្តង់ដារបច្ចេកទេសអប្បបរមា
- #២១០ ស្តង់ដារគុណភាពទឹក
- #០៦៩ តម្លៃទឹក

និងគោលការណ៍ណែនាំស្តីពីទឹកស្អាតក្នុងទីក្រុង។

ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមសំខាន់ៗរួមមានធនធានមនុស្ស និងសមត្ថភាពទាក់ទងនឹងបទប្បញ្ញត្តិ ក៏ដូចជាដើមទុនវិនិយោគនៅមានកម្រិត។

មុខងារនៃការផ្គត់ផ្គង់ទឹកស្អាតគឺស្ថិតនៅក្រោមការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍។ ការិយាល័យនេះគឺជាកន្លែងដែលមុខងារពាក់ព័ន្ធក្រោម MRD និង MISTI ត្រូវបានផ្ទេរ។ សម្រាប់ MRD មុខងារដែលបានផ្ទេរគឺ ‘ការសាងសង់ ជួសជុល ថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ’ ចំណែកសម្រាប់ MISTI មុខងារដែលបានផ្ទេរ 'គឺការគ្រប់គ្រងប្រព័ន្ធទឹកតាមបំពង់ (បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណ)'។

[3] ផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទឆ្នាំ ២០១៩-២០២៣

យោងតាមអនុក្រឹត្យឆ្នាំ២០១៩ មុខងារចំនួន៤ ត្រូវបានផ្ទេរពី MRD ទៅរដ្ឋបាលក្រុង ស្រុក រួមមាន

- ការអភិវឌ្ឍផ្លូវជនបទ
- ការគ្រប់គ្រង និងការផ្គត់ផ្គង់ទឹកជនបទ
- ការគ្រប់គ្រង និងផ្តល់អនាម័យជនបទ
- ការគ្រប់គ្រងទីផ្សារសហគមន៍

សម្រាប់មុខងារផ្គត់ផ្គង់ទឹក មានអនុមុខងារមួយគឺ "ការសាងសង់ ជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកជនបទ"។

សម្រាប់ MISTI មុខងារពីរត្រូវបានផ្ទេរទៅឱ្យរដ្ឋបាល ស្រុក/ក្រុង រួមមាន

1. ការផ្គត់ផ្គង់ទឹកស្អាត និង
2. ការផ្តល់សេវារដ្ឋបាលជាក់លាក់

មុខងារទីមួយគឺជា "ការគ្រប់គ្រងប្រព័ន្ធទឹកតាមបំពង់ (បន្ទាប់ពីទទួលបានអាជ្ញាប័ណ្ណ)។ មុខងារទីពីរ សំដៅលើការផ្តល់អាជ្ញាប័ណ្ណអាជីវកម្មខ្នាតតូចដែលមានហានិភ័យទាប និងតម្លៃវិនិយោគតិចជាង ៨០លានរៀល (២ម៉ឺនដុល្លារ)។

មានព័ត៌មានតិចស្តីអំពីការផ្ទេរមុខងាររបស់ MISTI បើប្រៀបធៀបទៅនឹង MRD។ នេះគឺដោយសារតែ MISTI គឺជាក្រសួងថ្មីមួយ។ ផ្ទុយទៅវិញ តួនាទីរបស់រដ្ឋបាលក្រុងស្រុកគឺមាននៅក្នុងប្រកាសរបស់ MISTI និងនីតិវិធីសម្រាប់គ្រប់គ្រងប្រតិបត្តិករទឹកឯកជន។ ក្នុងចំណោមប្រកាស និងគោលការណ៍ណែនាំទាំងអស់ ប្រកាសលេខ៤៦១ (២០១៤) គឺជាប្រកាសដ៏សំខាន់បំផុត ដោយមានបទប្បញ្ញត្តិជាក់លាក់ស្តីពីតួនាទីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

វាត្រូវបានគេជឿជាក់ថា ការផ្ទេរមុខងារលើការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ទៅរដ្ឋបាលស្រុក/ក្រុង ជាការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅរដ្ឋបាលស្រុក/ក្រុង។

ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលមូលដ្ឋានក្នុងការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពទទួលបានទឹកស្អាត និងសុវត្ថិភាពនៅមានកម្រិតនៅឡើយ ដោយសារកត្តាខាងក្រោម៖

- អំណាចដែលផ្ទេរទៅឱ្យរដ្ឋបាលមូលដ្ឋានទាក់ទងនឹងទឹកស្អាតតាមបំពង់ គឺមានភាពរឹតត្បិតពេកក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព។
- រដ្ឋបាលស្រុក/ក្រុង មិនត្រូវបានផ្តល់នូវមធ្យោបាយសមស្របដើម្បីអនុវត្តមុខងារ។
- រដ្ឋបាលមូលដ្ឋាន នៅខ្វះខាតធនធានដើម្បីអនុវត្តមុខងារថ្មីនេះឱ្យបានជោគជ័យ។

ខណៈពេលសម្របសម្រួលការងារផ្គត់ផ្គង់ទឹកស្អាត រដ្ឋបាលស្រុក/ក្រុង បានប្រឈមនឹងបញ្ហាមួយចំនួនដូចជា៖

- ចំណាកស្រុករបស់ប្រជាពលរដ្ឋ
- កង្វះការចូលរួមរបស់ប្រជាពលរដ្ឋដោយសារ ទម្លាប់ប្រពៃណី និងចំណេះដឹងក្នុងការប្រើប្រាស់ទឹក និងស្ថានភាពសេដ្ឋកិច្ច
- ការផ្សព្វផ្សាយ និងការលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋមូលដ្ឋាននៅមានកម្រិត ដោយសារស្ថានភាពភូមិសាស្ត្រ និងកត្តាថវិកា
- ខ្វះឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ធ្វើការតេស្តគុណភាពទឹក
- ប្រភពទឹកគ្មាននិរន្តរភាព និងខ្វះខាតនៅរដូវប្រាំង
- សមត្ថភាពនៃក្រុមការងារបច្ចេកទេសក្នុងការដឹកនាំ និងសម្របសម្រួលដល់វិស័យនេះនៅមានកម្រិត

សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ពួកគាត់មានតួនាទីយ៉ាងសំខាន់ និងសក្ដានុពលខ្លាំងក្នុងការបង្កើនការវិនិយោគទឹកឯកជនបន្ថែមទៀត និងកាត់បន្ថយបន្ទុកនៃការវិនិយោគសាធារណៈ ឬការផ្ដល់មូលនិធិ។ ប្រព័ន្ធផ្គត់ផ្គង់ទឹកឯកជនខ្នាតតូចនៅកម្ពុជាភាគច្រើនត្រូវបានផ្ដួចផ្ដើមដោយវិស័យឯកជន ជាជាងត្រូវបានស្នើសុំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការឆ្លើយតបទៅនឹងតម្រូវការក្នុងតំបន់។

ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនភាគច្រើនជាធម្មតាប្រើប្រាស់ហិរញ្ញវត្ថុផ្ទាល់ខ្លួនធ្វើការរចនា សាងសង់ និងប្រតិបត្តិការប្រព័ន្ធផ្គត់ផ្គង់ទឹកដោយខ្លួនឯង ហើយបានប្រឈមមុខនឹងបញ្ហាជាច្រើន រួមទាំង

- ការខូចខាតប្រព័ន្ធផ្គត់ផ្គង់ទឹកតាមបំពង់ដោយគ្មានសំណង
- មូលនិធិវិនិយោគមិនគ្រប់គ្រាន់
- តួនាទី និងការទទួលខុសត្រូវមិនច្បាស់លាស់របស់អាជ្ញាធរមូលដ្ឋាន
- ប្រភពទឹកគ្មាននិរន្តរភាព
- ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រមិនអំណោយផល
- ដង់ស៊ីតេគ្រួសារទាប
- មិនមានឆន្ទៈក្នុងការប្រើប្រាស់ទឹកស្អាតតាមបំពង់របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

## លទ្ធផលនៃការស្ទង់មតិ

លទ្ធផលនៃការស្ទង់មតិជាមួយ២០៦គ្រួសារ (ក្នុងនោះអ្នកឆ្លើយសំណួរចំនួន ១៤៣នាក់ជាស្ត្រី ហើយ ៥០នាក់ស្ថិតក្នុងចំណោមជនងាយរងគ្រោះ) បង្ហាញថាប្រហែល ១៧% នៃពួកគាត់មិនមានទឹកស្អាតតាមបំពង់ភ្ជាប់ទៅផ្ទះរបស់ពួកគាត់ទេ ហើយភាគច្រើននៃពួកគាត់ប្រើប្រាស់ទឹកអណ្ដូង។ ការគ្មានចំណាប់អារម្មណ៍ពីប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ការមិនចាប់អារម្មណ៍របស់អ្នកភូមិក្នុងការប្រើប្រាស់ទឹកស្អាតតាមបំពង់ និងប្រភពទឹកមិនមាននិរន្តរភាព គឺជាអ្វីដែលពួកគាត់បានលើកឡើងភាគច្រើន ថានាំឱ្យមិនមានទឹកស្អាតតាមបំពង់នៅក្នុងតំបន់របស់ពួកគាត់។

- ស្ទើរតែ ៥០% នៃគ្រួសារដែលទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ បានត្អូញត្អែរមួយចំនួនទៅកាន់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ទាក់ទងនឹងអស្ថិរភាពនៃគុណភាព និងបរិមាណនៃការផ្គត់ផ្គង់ទឹក ថ្លៃទឹកខ្ពស់ ការឆ្លើយតបយឺតយ៉ាវ និងការលំបាកក្នុងការទាក់ទង។
- ទោះយ៉ាងណាក៏ដោយ ប្រហែល ១៧% នៃអ្នកត្អូញត្អែរ ទទួលបានភាពមិនពេញចិត្តចំពោះការឆ្លើយតបរបស់ប្រតិបត្តិករ ខណៈដែលជិត ៤០% ផ្សេងទៀតនៃពួកគាត់មិនបានទទួលការឆ្លើយតបអ្វីទាល់តែសោះ។
- ជាងនេះទៅទៀត ២០% នៃគ្រួសារដែលទទួលបានការផ្គត់ផ្គង់ទឹកស្អាតតាមបំពង់ក៏បានទាក់ទងអាជ្ញាធរមូលដ្ឋាន ដើម្បីជូនដំណឹងអំពីបញ្ហាទាក់ទងនឹងការផ្គត់ផ្គង់ទឹកផងដែរ។
- ប៉ុន្តែ ៧៦,៥% នៃពួកគាត់បាននិយាយថា អាជ្ញាធរមូលដ្ឋានបានព្យាយាមសម្របសម្រួលបញ្ហា ប៉ុន្តែមិនមានភាពប្រសើរឡើងឡើយ។
- ខណៈដែល ២៣,៥% ផ្សេងទៀតបាននិយាយថា អាជ្ញាធរមូលដ្ឋានមិនបានចាត់វិធានការណាមួយឡើយ។

ដោយសារកូវីដ-១៩ ថវិការដ្ឋាភិបាលសម្រាប់ការផ្តល់សេវាសាធារណៈត្រូវបានកាត់បន្ថយ។ ការថយចុះនេះបានប៉ះពាល់ដល់ក្រសួង និងស្ថាប័នដែលកំពុងអនុវត្តសកម្មភាពរបស់ខ្លួនក្នុងការអភិវឌ្ឍវិស័យនេះ ខណៈដែលប្រជាពលរដ្ឋដែលគ្មានលទ្ធភាពទទួលបានសេវាទឹកស្អាត និងអនាម័យ មិនអាចអនុវត្តការលាងដៃញឹកញាប់បានឡើយ ដោយសារកង្វះទឹកស្អាត ដែលបង្កឱ្យមានបញ្ហាប្រឈម និងភាពងាយរងគ្រោះកាន់តែច្រើនក្នុងការទប់ទល់នឹងកូវីដ-១៩។



ផលប៉ះពាល់ផ្សេងទៀតត្រូវបានលើកឡើង រួមមានភាពយឺតយ៉ាវនៃការអភិវឌ្ឍន៍វិស័យផ្គត់ផ្គង់ទឹកស្អាត និងអត្រាពង្រីកការគ្របដណ្តប់ ការផ្អាកសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ការប្រើប្រាស់ប្រព័ន្ធអនឡាញក្នុងការបណ្តុះបណ្តាលដែលមិនសូវមានប្រសិទ្ធភាព ហើយនិងការថយចុះប្រាក់ចំណូល ក៏ដូចជាធន្ទះក្នុងការវិនិយោគរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។

# ៥. អនុសាសន៍

ដើម្បីធានាបាននូវភាពជាដៃគូប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋបាលមូលដ្ឋាន និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ក្រុមការងារបានបង្កើតអនុសាសន៍មួយចំនួន៖

## I. រដ្ឋបាលស្រុក និងឃុំ

- បង្កើនថវិកានៅកម្រិតស្រុក និង ឃុំ
- ជាមួយនឹងថវិកាមានកំណត់ សកម្មភាពសំខាន់ៗគួរតែត្រូវបានផ្តល់អាទិភាព
- រៀបចំយុទ្ធនាការប្រមូលមូលនិធិ
- ពង្រឹងទំនាក់ទំនងរវាង ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអាជ្ញាធរ តាមរយៈការប្រជុំជាប្រចាំ
- រៀបចំវេទិកាសាធារណៈ និងត្រួតពិនិត្យជាប្រចាំ
- ត្រូវមានអ្នកជំនាញទឹក និងអនាម័យមូលដ្ឋានជាប្រចាំ
- កសាងសមត្ថភាពបុគ្គលិកលើការធ្វើផែនការ ការគ្រប់គ្រង ការត្រួតពិនិត្យ និងការសម្របសម្រួល
- បញ្ចូល ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់ការងាររៀបចំផែនការអភិវឌ្ឍន៍ស្រុក/ឃុំ
- ធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹងបន្ថែមទៀតដល់សហគមន៍មូលដ្ឋានទាក់ទងនឹងអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត និងការការពារប្រភពទឹក

## II. ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត

- ទទួលខុសត្រូវចំពោះរាល់បញ្ហាពាក់ព័ន្ធដែលលើកឡើងដោយអ្នកប្រើប្រាស់ទឹក
- ពង្រឹងសមត្ថភាពបុគ្គលិករបស់ខ្លួនក្នុងការប្រតិបត្តិការ និងការគ្រប់គ្រងដោយអនុលោមតាមបទប្បញ្ញត្តិ
- ផ្តល់ទិន្នន័យដល់អាជ្ញាធរឃុំ/ស្រុក រួមទាំងផែនទីបណ្តាញទុយោ
- សហការជាមួយអាជ្ញាធរឃុំ និងក្រុមហ៊ុនសាងសង់ផ្លូវក្នុងមូលដ្ឋាន ដើម្បីកាត់បន្ថយការខូចខាតបណ្តាញទុយោ

## III. រដ្ឋបាលខេត្ត

- ជំរុញការវិនិយោគលើការផ្គត់ផ្គង់ទឹកស្អាត
- កៀរគរធនធានដើម្បីវិនិយោគលើការងារផ្គត់ផ្គង់ទឹកស្អាត
- សម្របសម្រួលវិនិយោគិនក្នុងការអនុវត្តគម្រោងរបស់ពួកគេ

## IV. ក្រសួង

- បន្តពិនិត្យ និងកែលម្អបន្ថែមទៀតទៅលើនីតិវិធីក្នុងការផ្តល់អាជ្ញាប័ណ្ណ
- ពន្លឿនការអភិវឌ្ឍ និងការចេញសេចក្តីណែនាំផ្លូវច្បាប់លម្អិត គោលការណ៍ណែនាំបច្ចេកទេស និងសៀវភៅណែនាំប្រតិបត្តិការលើបញ្ហាពាក់ព័ន្ធ
- ផ្សព្វផ្សាយឲ្យបានទូលំទូលាយដល់រដ្ឋាភិបាលមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីឲ្យពួកគេយល់ច្បាស់អំពីភារកិច្ច តួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ព្រមទាំងនីតិវិធីផ្សេងៗទៀត

## V. ស្ថាប័នពាក់ព័ន្ធ

- ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នាក្នុងលក្ខណៈសមាហរណកម្ម ដើម្បីលុបបំបាត់នូវផ្នែកដែលត្រួតគ្នានៃប្រតិបត្តិការ ក៏ដូចជាតួនាទី និងភារកិច្ច
- ចាំបាច់ត្រូវបង្កើតវេទិកាទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព ដែលភ្នាក់ងារពាក់ព័ន្ធ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត អាចទាក់ទងសម្របសម្រួល និងចែករំលែកព័ត៌មានបានប្រសើរជាងមុន

អង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព (CSW) គឺជាអង្គការក្នុងស្រុកមិនរកប្រាក់ចំណេញមួយដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៧ ដើម្បីបំពេញតម្រូវការក្នុងការបង្កើនធនធានមនុស្ស និងបង្កើតភាពច្នៃប្រឌិតក្នុងវិស័យគ្រប់គ្រងធនធានទឹក (WRM) និង វិស័យទឹកស្អាត និងអនាម័យ (WASH) ដែលមានគោលបំណងក្នុងការកែលម្អការគ្រប់គ្រងធនធានទឹក និង ការផ្តល់សេវាទឹកស្អាត និងអនាម័យ ដល់ប្រជាពលរដ្ឋដែលមិនមានលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យគ្រប់គ្រាន់ និងមានសុវត្ថិភាព។

## អង្គការប្រើប្រាស់ទឹកប្រកបដោយចីរភាព


#២២៥ ជាន់ទី២ ផ្លូវ៦៣ កែង ៣៣៤ សង្កាត់បឹងកេងកង១
ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ
+៨៥៥ (០)៧៧ ៦០៧ ៧០៧
https://centerforsustainablewater.org/